**ក្រសួងមហាផ្ទៃ**
**បណ្ឌិត្យសភានគរបាលកម្ពុជា**

លេខ: ០៥៤ ខបក

**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

ថ្ងៃព្រហស្បតិ៍ ២កើត ខែអាសាឍ ឆ្នាំកុរ ឯកស័ក ព.ស២៥៦៣
ជីតជួ ថ្ងៃទី ០៤ ខែកក្កដា ឆ្នាំ២០១៩

## សូមគោរពជូន

## សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

**តាមរយៈ**: ឯកឧត្តម សន្តិបណ្ឌិត រដ្ឋលេខាធិការទទួលបន្ទុក ។

**កម្មវត្ថុ** : សូមគោរពរាយការណ៍អំពីដំណើរការរៀបចំសេចក្តីព្រាងប្រកាស ស្តីពីការបង្កើតឯកសណ្ឋាន និងសញ្ញាសម្គាល់ សម្រាប់និស្សិតនិងសិស្សនគរបាលជាតិនៃបណ្ឌិត្យសភានគរបាលកម្ពុជា និងគោរពស្នើសុំមតិដឹកនាំ ។

**យោង** : ចំណារឯកភាពដ៏ខ្ពង់ខ្ពស់របស់ **សម្តេចក្រឡាហោម** ចុះថ្ងៃទី ៣០ ខែមករា ឆ្នាំ២០១៨ ។

តបតាមកម្មវត្ថុនិងយោងខាងលើ ខ្ញុំបាទសូមគោរពជម្រាបជូន **សម្តេចក្រឡាហោម** មេត្តាជ្រាបដ៏ខ្ពង់ខ្ពស់ថា ៖ យោងតាមចំណារឯកភាពនិងមតិណែនាំដ៏ខ្ពង់ខ្ពស់របស់ **សម្តេច** បណ្ឌិត្យសភានគរបាលកម្ពុជា បានរៀបចំសេចក្តីព្រាងប្រកាស ស្តីពីការបង្កើតឯកសណ្ឋាននិងសញ្ញាសម្គាល់ សម្រាប់និស្សិតនិងសិស្សនគរបាលជាតិ និងបានដាក់ឆ្លងកិច្ចប្រជុំពិភាក្សាក្នុងក្របខណ្ឌបណ្ឌិត្យសភា ចំនួន០៣លើក កិច្ចប្រជុំដឹកនាំដោយ **ឯកឧត្តម សន្តិបណ្ឌិត ចាន់ អ៊ាន** ចំនួន០២លើក និងកិច្ចប្រជុំបច្ចេកទេស ចំនួន០១លើក ដោយមានសមាសភាពចូលរួមប្រជុំរួមមាន តំណាងមកពីបណ្ឌិត្យសភា អគ្គនាយដ្ឋានភស្តុភារនិងហិរញ្ញវត្ថុ ក្រុមប្រឹក្សានីតិកម្ម អគ្គលេខាធិការដ្ឋាន និងនាយកដ្ឋានបុគ្គលិក។

ក្នុងកិច្ចប្រជុំទាំងនេះ សមាជិកអង្គប្រជុំទាំងអស់បានគាំទ្រលើការរៀបចំសេចក្តីព្រាងប្រកាសនេះ ដែលមានលក្ខណៈត្រឹមត្រូវទាំងទិដ្ឋភាពច្បាប់និងទិដ្ឋភាពបច្ចេកទេស ព្រមទាំងបានឯកភាពលើខ្លឹមសារនៃសេចក្តីព្រាងប្រកាស និងឧបសម្ព័ន្ធ ដូចបានគោរពភ្ជាប់ជូនជាមួយ។

ចំពោះការចំណាយលើការកាត់ឯកសណ្ឋាន មិនធ្វើប៉ះពាល់ដល់ថវិការដ្ឋបន្ថែមទៀតទេ ពីព្រោះអង្គប្រជុំបានឯកភាព ដូចខាងក្រោម ៖

១. ការកាត់ឯកសណ្ឋានរបស់សិស្សនគរបាល ជាបន្ទុករបស់សិស្សម្នាក់ៗ

២. ចំពោះនិស្សិតនាយនគរបាលបន្តវេន អគ្គនាយដ្ឋានភស្តុភានិងហិរញ្ញវត្ថុ បានឯកភាពបង្វែរបបឯកសណ្ឋានប្រចាំឆ្នាំ ឱ្យទៅសាមីខ្លួននិស្សិតម្នាក់ៗ ដើម្បីជំនួសឯកសណ្ឋានសិក្សា និងហ្វឹកហាត់ថ្មី ដោយគ្រាន់តែផ្លាស់ប្តូរសញ្ញាសម្គាល់ និងពណ៌មួកតែប៉ុណ្ណោះ ។

សេចក្តីព្រាងប្រកាសនេះ ត្រូវបានបង្កើតឡើងក្នុងគោលបំណង និងហេតុផល ដូចខាងក្រោម៖

- កំណត់អត្តសញ្ញាណនិងពង្រឹងវិន័យនិស្សិត និងសិស្សនគរបាល នៅពេលកំពុងសិក្សានិងហ្វឹកហាត់ ព្រមទាំងជួយសម្រួលដល់ការងារគ្រប់គ្រងរបស់សាលាឱ្យមានប្រសិទ្ធភាព

- លើកកម្ពស់កិត្យានុភាពបណ្ឌិត្យសភា និងអាចប្រៀបធៀបបានជាមួយស្ថាប័នបណ្តុះ-បណ្តាលកងកម្លាំងនគរបាលនៃប្រទេសនានាក្នុងក្របខ័ណ្ឌអាស៊ាន និងតំបន់ ដែលជាផ្នែកមួយនៃកំណែទម្រង់របស់បណ្ឌិត្យសភា
- ដើម្បីឱ្យសិស្សនគរបាលដែលមិនទាន់មានសិទ្ធិស្របច្បាប់ក្នុងការប្រើឯកសណ្ឋានមន្ត្រីនគរបាល អាចប្រើប្រាស់ឯកសណ្ឋាននេះសម្រាប់ពេលសិក្សា និងហ្វឹកហាត់ ។

ហេតុនេះ បណ្ឌិត្យសភាត្រូវបង្កើតឯកសណ្ឋានសម្រាប់អ្នកសិក្សាដោយឡែកពីឯកសណ្ឋានមន្ត្រីនគរបាលជាតិ ស្របតាមបទពិសោធន៍ ដែលអនុវត្តជាទូទៅទាំងក្របខណ្ឌជាតិ និងអន្តរជាតិ។

ទោះជាយ៉ាងនោះក្តី **ឯកឧត្តម សន្តិបណ្ឌិត ចាន់ អ៊ាន** យល់ឃើញថា សេចក្តីព្រាងប្រកាសនេះមិនទាន់អាចសម្រេចបាននៅក្នុងកម្រិតឯកឧត្តមរដ្ឋលេខាធិការបានទេ។ ហេតុនេះ សេចក្តីព្រាងប្រកាសនេះគួរដាក់ឆ្លងកិច្ចប្រជុំចុងក្រោយ ដឹកនាំដោយ **សម្តេចក្រឡាហោម** ដោយមានការចូលពីរដ្ឋលេខាធិការ និងប្រធានអង្គភាពពាក់ព័ន្ធ ដើម្បីពិភាក្សានិងផ្តល់យោបល់លើសេចក្តីព្រាងប្រកាសនេះ។

ក្នុងន័យនេះ ខ្ញុំបាទសូមគោរពស្នើសុំមតិដឹកនាំដ៏ខ្ពង់ខ្ពស់ពី **សម្តេចក្រឡាហោម** លើសំណើចំនួន០២ ដូចខាងក្រោម៖

ទី១. គោរពអញ្ជើញ **សម្តេច** ដឹកនាំកិច្ចប្រជុំ ដើម្បីពិនិត្យនិងសម្រេចលើសេចក្តីព្រាងប្រកាស និងឧបសម្ព័ន្ធដូចបានគោរពភ្ជាប់ជូនជាមួយ ។ ឬ

ទី២. គោរពស្នើសុំ **សម្តេច** ពិនិត្យ និងសម្រេចលើសេចក្តីព្រាងប្រកាសនេះ និងឧបសម្ព័ន្ធ។

អាស្រ័យដូចបានគោរពជម្រាបជូនខាងលើសូម **សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ** មេត្តាពិនិត្យ និងសម្រេចដ៏ខ្ពង់ខ្ពស់។

សូម **សម្តេចក្រឡាហោម** មេត្តាទទួលនូវសេចក្តីគោរពដ៏ខ្ពង់ខ្ពស់ពីខ្ញុំបាទ ។

**ប្រធានបណ្ឌិត្យសភានគរបាលកម្ពុជា**

នាយឧត្តមសេនីយ៍ សាស្ត្រាចារ្យ **សេង ផល្លី**

**បានឃើញ**...........................

**គោរពជូនសម្តេចក្រឡាហោមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ មេត្តាពិនិត្យនិងសម្រេចដ៏ខ្ពង់ខ្ពស់។**

ថ្ងៃ........ខែ........ឆ្នាំ........ព.ស.២៥៦៣.

រាជធានីភ្នំពេញ.ថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ២០១៩

**រដ្ឋលេខាធិការ**

សន្តិបណ្ឌិត.**ចាន់_អ៊ាន**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**ក្រសួងមហាផ្ទៃ**

លេខ: ៦៤២៧ ប្រក.

# ប្រកាស
## ស្តីពី
## ការបង្កើតឯកសណ្ឋាន និង សញ្ញាសម្គាល់ សម្រាប់និស្សិតនិងសិស្សនគរបាលជាតិ នៃបណ្ឌិត្យសភានគរបាលកម្ពុជា

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០០៥/៤៤៤ ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ២០០៥ ស្តីពីការកែសំរួលមាត្រា៨ មាត្រា១០ នៃព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់ប្រធានបណ្ឌិត្យសភានគរបាលកម្ពុជា

## សម្រេច

**ប្រការ១.–**

ត្រូវបានបង្កើតឯកសណ្ឋាន និង សញ្ញាសម្គាល់ សម្រាប់និស្សិតនិងសិស្សនគរបាលជាតិទាំងពីរភេទ នៃបណ្ឌិត្យសភានគរបាលកម្ពុជា ដើម្បីប្រើក្នុងពេលសិក្សា និង ពេលហ្វឹកហាត់ ឬ ក្នុងពិធីផ្សេងៗទៀត តាមការកំណត់របស់បណ្ឌិត្យសភានគរបាលកម្ពុជា ។

**ប្រការ២.-**

ឯកសណ្ឋាននិស្សិតនិងសិស្សនគរបាលជាតិមាន២ប្រភេទគឺ **ឯកសណ្ឋានសិក្សា** និង **ឯកសណ្ឋានហ្វឹកហាត់** ដែលបែងចែកជា ២កម្រិត ដូចខាងក្រោម ៖

១-ឯកសណ្ឋាននិស្សិតនគរបាលជាតិ រួមមានឯកសណ្ឋានសម្រាប់និស្សិតថ្នាក់បរិញ្ញាបត្រ និង និស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ។

២-ឯកសណ្ឋានសិស្សនគរបាលជាតិ ។

**ប្រការ៣.-**

គំរូឯកសណ្ឋាន និង គំរូសញ្ញាសម្គាល់ត្រូវបានកំណត់ក្នុងឧបសម្ព័ន្ធនៃប្រកាសនេះ ។

**ប្រការ៤.-**

ឯកសណ្ឋានសិក្សាសម្រាប់និស្សិតនិងសិស្សនគរបាលជាតិទាំងពីរភេទ ដែលប្រើក្នុងពេលសិក្សាផ្នែកទ្រឹស្តី ត្រូវកំណត់ដូចខាងក្រោម ៖

១- អាវ ខោ និងខ្សែក្រវ៉ាត់សម្រាប់បុរស និងនារី មានលក្ខណៈរួម ៖

- អាវដៃវែងពណ៌កាគី កឱប ប៉ូលស្មា និងចុងដៃអាវឱបមានឡេវមួយគ្រាប់សម្រាប់បិត។ អាវនេះកាត់ស្រុងជើងអាវវៀល មានហោប៉ៅចំនួនពីរជាហោប៉ៅប៉ះដែលនៅចំកណ្តាលមានផ្នត់មួយ និងគម្របហោប៉ៅអាវមានរាងស្លឹកពោធិ៍។ ឡេវអាវមានពណ៌កាគី និងមានចំនួន៥គ្រាប់។ អាវមានជីបបណ្តោយខ្នងអាវទាំងពីរខាង។ អាវនេះ ពាក់ពីលើ អាវយឺតពណ៌ស កម្ពុលខាងក្នុង ។
- ខោជើងវែងពណ៌កាគី ថ្នេរបង្កប់ ចង្កេះត គ្មានក្លី។ ខោមានហោប៉ៅបួន ហោប៉ៅក្រោយចំនួនពីរដេរបង្កប់គ្មានគម្របនិងចោះរន្ធដាក់ឡេវចំនួនមួយគ្រាប់។ ហោប៉ៅចំហៀងទាំងពីរខាងដេរបង្កប់តាមថ្នេរខោ ។
- ខ្សែក្រវ៉ាត់តូចពណ៌ខ្មៅមានក្បាលលាតពណ៌ទឹកប្រាក់ ដោយគ្មានរូបលម្អអ្វីទាំងអស់ ។

២- មួក និង ស្បែកជើង មានលក្ខណៈដោយឡែកពីគ្នា ៖

- មួកបុរសមានទម្រង់ជាមួកកាស្កេតធ្វើអំពីក្រណាត់។ ជើងមួកមានវណ្ឌព័ទ្ធជុំវិញ។ ពណ៌មួក និងពណ៌វណ្ឌមួកត្រូវបានកំណត់តាមកម្រិតឯកសណ្ឋាននិងឆ្នាំសិក្សា ដូចមានចែងក្នុងប្រការ៧នៃប្រកាសនេះ។ ក្បាំងមួកមានពណ៌ខ្មៅ។ នៅលើមុខមួក មានដាក់រូបព្រះសង្ហារពណ៌ទឹកប្រាក់ ទំហំកម្ពស់ ៧៨ ម.ម និងទទឹង ៧១ ម.ម ។
- មួកនារីមានទម្រង់ជាមួកសំបុកធ្វើអំពីក្រណាត់។ ជើងមួកមានវណ្ឌផ្នែកខាងមុខ។ ពណ៌មួក និងពណ៌វណ្ឌមួកត្រូវបានកំណត់តាមកម្រិតឯកសណ្ឋាននិងឆ្នាំសិក្សា ដូចមានចែងក្នុងប្រការ៧នៃប្រកាសនេះ។ ក្បាំងមួកមានពណ៌ខ្មៅ។ នៅលើមុខមួក មានដាក់រូបព្រះសង្ហារពណ៌ទឹកប្រាក់ ទំហំកម្ពស់ ៥៣ ម.ម និងទទឹង ៥៤ ម.ម ។
- ស្បែកជើងបុរសជាស្បែកជើងឃ្លុបកខ្លី ពណ៌ខ្មៅ និងចងខ្សែ។ កែងស្បែកជើងមានជាប់បន្ទះលោហៈរាងប៉ោង ចាប់ជាប់នៅចំហៀងកែងផ្នែកខាងក្នុង និងស្រោមជើងពណ៌ខ្មៅ ។
- ស្បែកជើងនារីជាស្បែកជើងឃ្លុបកខ្លី ពណ៌ខ្មៅ ចងខ្សែ និងមានបាតកែងរាបស្មើដោយប៉ានបន្ទះលោហៈរាងប៉ោង ចាប់ជាប់នៅចំហៀងកែងផ្នែកខាងក្នុង និងស្រោមជើងពណ៌ខ្មៅ។

**ប្រការ៥.—**

ឯកសណ្ឋានហ្វឹកហាត់ សម្រាប់និស្សិតនិងសិស្សនគរបាលជាតិទាំងពីរភេទ ដែលប្រើសម្រាប់សិក្សាប្រតិបត្តិលើទីលានក្រៅថ្នាក់ ត្រូវកំណត់ដូចខាងក្រោម ៖

- អាវដៃវែងពណ៌បៃតងចាស់ មានហោប៉ៅចំនួនបួន ក្នុងនោះមានហោប៉ៅខាងលើពីរ និងហោប៉ៅខាងក្រោមពីរដែលជាហោប៉ៅស្បោងមានជីបមាត់ចាបចំកណ្តាល។ តួហោប៉ៅទាំងបួនមានគម្របបញ្ឆិតសន្ទះអណ្តាត ដោយចោះរន្ធដាក់ឡេវបង្កប់មួយគ្រាប់សម្រាប់ហោប៉ៅអាវលើនីមួយៗ និងពីរគ្រាប់សម្រាប់ហោប៉ៅអាវក្រោមនីមួយៗ។ ឡេវមានពណ៌ដូចអាវ មានចំនួនប្រាំគ្រាប់ ជាឡេវបង្កប់។ ដៃអាវជាប្រភេទដៃបំពង់ដែលនៅចុងដៃអាវមានប៉ូលមួយដាក់ឡេវចំនួនពីរគ្រាប់។ នៅត្រង់ចង្កេះអាវទាំងពីរខាងមានប៉ូលទទឹងអាវ ភ្ជាប់ដោយឡេវម្ខាងចំនួនពីរគ្រាប់ដែលមានពណ៌ដូចអាវ ។ អាវនេះ ពាក់ពីលើអាវយឺតពណ៌បៃតងចាស់កមូលខាងក្នុង ។
- ខោជើងវែងមានជីបក្បាលជង្គង់ហើយចុងជើងខោមានខ្សែចងរឹត។ ចង្កេះលាតនិងនៅទាំងពីរខាងចង្កេះខោមានខ្សែរឹត។ ខោមានហោប៉ៅចំនួនប្រាំមួយគឺ៖
    - ហោប៉ៅខាងក្រោយមានចំនួនពីរជាហោប៉ៅកាត់មានគម្របបញ្ឆិតសន្ទះអណ្តាតដោយចោះរន្ធដាក់ឡេវមួយគ្រាប់
    - ហោប៉ៅចំហៀងមានចំនួនពីរជាហោប៉ៅបញ្ឆិត
    - ហោប៉ៅជង្គង់មានចំនួនពីរជាហោប៉ៅស្បោង មានជីបផ្នត់ពីរ តួហោប៉ៅជ្រុង គម្របបញ្ឆិតមានសន្ទះអណ្តាតដោយចោះរន្ធដាក់ឡេវចំនួនពីរគ្រាប់។ ឡេវពណ៌ដូចខោ។
- មួកប៉េរ៉េធ្វើអំពីក្រណាត់មានពណ៌កំណត់តាមកម្រិតឯកសណ្ឋាន និងឆ្នាំសិក្សា ដែលមានចែងក្នុងប្រការ៧នៃប្រកាសនេះ ។ រឹមមួកមានពណ៌ខ្មៅ។ នៅចំហៀងផ្នែកខាងឆ្វេងមួក មានរូបព្រះសង្ខារ ទ្រដោយកម្រងគួរស្រូវមាន រាងជាស្នែងក្របីពណ៌ទឹកប្រាក់ទំហំកម្ពស់ ៤៥ ម.ម និងទទឹង ៥៥ ម.ម។ មួកមានចោះរន្ធចំនួនពីរផ្នែកចំហៀងខាងស្តាំ និងមានខ្សែចងរឹត។
- ខ្សែក្រវាត់តូចពណ៌ខ្មៅ មានក្បាលលាតពណ៌ទឹកប្រាក់ ដោយគ្មានរូបលម្អអ្វីទាំងអស់
- ខ្សែក្រវាត់សាំងទៀរ៉ុង ពណ៌បៃតងចាស់ ក្រវាត់ពីក្រៅអាវ
- ស្បែកជើងឃ្លុបកវែងពណ៌ខ្មៅ ចងខ្សែ ដោយប៉ានបន្ទះលោហៈនៅចំហៀងកែងផ្នែកខាងក្នុង និងមានស្រោមជើងពណ៌ខ្មៅ ។

**ប្រការ៦.—**

សញ្ញាសម្គាល់នៃឯកសណ្ឋាននិស្សិតនិងសិស្សនគរបាលជាតិទាំងពីរភេទ មានលក្ខណៈរួម និងត្រូវកំណត់ដូចខាងក្រោម ៖

១- សញ្ញាស្មាអាវ

សញ្ញាស្មាអាវ ធ្វើអំពីក្រណាត់ មានពណ៌ដូចមួកដែលកំណត់តាមកម្រិតឯកសណ្ឋាន និងឆ្នាំសិក្សា មានរាងទ្រវែង រៀវកណ្តាលនិងខាងចុងស្រួច។ ផ្នែកខាងលើមានឡេវព្រះសង្ខារពណ៌ទឹកប្រាក់ ផ្នែកកណ្តាល មានសញ្ញាពណ៌ទឹកប្រាក់ដែលជាផ្នែកកណ្តាលនៃនិមិត្តសញ្ញារបស់បណ្ឌិត្យសភានគរបាលកម្ពុជាទំហំកម្ពស់ ៥០ ម.ម និងទទឹង ២១ ម.ម និងផ្នែកខាងក្រោម មានអក្សរមូលសរសេរថា «ន» និងលេខពណ៌ទឹកប្រាក់ ដែលបញ្ជាក់ពីជំនាន់របស់និស្សិតឬសិស្សនគរបាលជាតិ កំពុងសិក្សា។ សញ្ញានេះ សម្រាប់ពាក់ជាប់លើប៉ូលស្មាទាំងពីរខាង ។

ខ្នាតសញ្ញាស្មាអាវ ៖

- បណ្តោយ ១៣០ ម.ម
- ទទឹងខាងដើម ៥៧ ម.ម
- ទទឹងកណ្តាល ៤៧ ម.ម
- ទទឹងខាងចុងកាច់ទៅចុងស្រួច ៤៤ ម.ម
- ប្រវែងបញ្ជិតជ្រុងលើ ៣០ ម.ម
- ឡេវរូបព្រះសង្ការអង្កត់ផ្ចិត ១៥ ម.ម
- អក្សរ «ជ» និងលេខ កម្ពស់ ១៨ ម.ម
- ពីចុងស្រួចមកឡេវប្រវែង ៦ ម.ម ។

២- បន្ទោងនិមិត្តសញ្ញាបណ្ឌិត្យសភានគរបាលកម្ពុជា

-ចំពោះឯកសណ្ឋានសិក្សា ៖ បន្ទោងនិមិត្តសញ្ញាបណ្ឌិត្យសភានគរបាលកម្ពុជា មានរាងជាមេដាយ ដែលមានស្បែកបន្ទោងប្រវែង ១០០ ម.ម បាតស្រួចពណ៌ខៀវចាស់។ នៅលើស្បែកបន្ទោងមាននិមិត្តសញ្ញាបណ្ឌិត្យសភានគរបាលកម្ពុជារាងមូលធ្វើពីលោហៈ អង្កត់ផ្ចិតប្រវែង ៤៩ ម.ម សម្រាប់ពាក់បន្តោកជាប់ឡេវហោប៉ៅអាវខាងស្តាំ ។

-ចំពោះឯកសណ្ឋានហ្វឹកហាត់ ៖ បន្ទោងនិមិត្តសញ្ញាបណ្ឌិត្យសភានគរបាលកម្ពុជា មានរាងជាមេដាយ ដែលមានប្រវែង ១០០ ម.ម បាតស្រួចពណ៌ខៀវចាស់ មាននិមិត្តសញ្ញាបណ្ឌិត្យសភានគរបាលកម្ពុជារាងមូល អង្កត់ផ្ចិតប្រវែង ៤៩ ម.ម ជាបន្ទោងក្រណាត់មានប៉ាក់ ដេរភ្ជាប់នឹងហោប៉ៅអាវលើផ្នែកខាងស្តាំ ។

៣- ស្លាកសញ្ញាបណ្ឌិត្យសភានគរបាលកម្ពុជា

ស្លាកសញ្ញាបណ្ឌិត្យសភានគរបាលកម្ពុជា ធ្វើអំពីក្រណាត់ ទម្រង់ស្រដៀងស្លឹកពោធិ៍ ពណ៌ផ្ទៃមេឃ ទំហំកម្ពស់ ៩៥ ម.ម និងទទឹង ៧៥ ម.ម រឹមព័ទ្ធជុំវិញពណ៌ទឹកប្រាក់ មានផ្នែកកណ្តាលនៃនិមិត្តសញ្ញាបណ្ឌិត្យសភានគរបាលកម្ពុជាពណ៌ទឹកប្រាក់ទំហំកម្ពស់ ៥៩ ម.ម និងទទឹង ៣២ ម.ម ផ្នែកខាងលើមានសរសេរថា "**បណ្ឌិត្យសភានគរបាលកម្ពុជា**" និងផ្នែកខាងក្រោមសរសេរជាភាសាអង់គ្លេសថា "POLICE ACADEMY OF CAMBODIA"។ ស្លាកសញ្ញានេះ សម្រាប់ដេរភ្ជាប់លើដៃអាវខាងស្តាំ ចុះពីថ្នេរស្មាចម្ងាយ ៧៥ ម.ម ។

៤- ស្លាកសញ្ញានិស្សិត និង សិស្សនគរបាលជាតិ

ស្លាកសញ្ញានិស្សិត និង សិស្សនគរបាលជាតិ ធ្វើអំពីក្រណាត់មានប៉ាក់រាងកោង ទំហំបណ្តោយខាងលើប្រវែង ១០៥ ម.ម បណ្តោយខាងក្រោមប្រវែង ៧០ ម.ម និងទទឹងប្រវែង ២៥ ម.ម មានរឹមព័ទ្ធជុំវិញពណ៌សទទឹងប្រវែង ១.៥ ម.ម នៅចំកណ្តាលមានផ្ទៃពណ៌ក្រហម ចន្លោះវណ្ឌពណ៌ខៀវលើក្រោម មានអក្សរមូលពណ៌ស សរសេរថា «**និស្សិតនគរបាលជាតិ**» សម្រាប់សម្គាល់និស្សិតនគរបាលជាតិ និង «**សិស្សនគរបាលជាតិ**» សម្រាប់សម្គាល់សិស្សនគរបាលជាតិ អក្សរកម្ពស់ ៨ ម.ម ។ ស្លាកសញ្ញានេះ សម្រាប់ដេរភ្ជាប់លើដៃអាវខាងឆ្វេង ចុះពីថ្នេរស្មាចម្ងាយ ៥០ ម.ម ។

៥- សញ្ញាកអាវ

-ចំពោះឯកសណ្ឋានសិក្សា ៖ សញ្ញាកអាវ ដែលជាផ្នែកកណ្តាលនៃនិមិត្តសញ្ញារបស់បណ្ឌិត្យសភានគរបាលកម្ពុជា ធ្វើពីលោហៈពណ៌ទឹកប្រាក់ទំហំកម្ពស់ ៣៥ ម.ម និងទទឹង ១៥ ម.ម ។ សញ្ញាកអាវនេះសម្រាប់ពាក់នៅលើចុងកអាវទាំងពីរខាង ។

-ចំពោះឯកសណ្ឋានហ្វឹកហាត់ ៖

សញ្ញាកអាវ រាងទ្រវែង ខាងដើមរាងមូល និងខាងចុងស្រួច ធ្វើពីក្រណាត់មានប៉ាក់ ផ្ទៃពណ៌ដូចម្លូក និងមានរឹមពណ៌ទឹកប្រាក់ព័ទ្ធជុំវិញ មានផ្នែកកណ្តាលនៃនិមិត្តសញ្ញាបណ្ឌិត្យសភានគរបាលកម្ពុជា ពណ៌ទឹកប្រាក់ ទំហំកម្ពស់ ៣៥ ម.ម និងទទឹង ១៥ ម.ម ។ សញ្ញាកអាវនេះ សម្រាប់ដេរភ្ជាប់នៅលើកអាវខាងស្តាំ ។

ខ្នាតសញ្ញាកអាវខាងស្តាំ ៖

- បណ្តោយ ៥២ ម.ម
- ទទឹង ៣២ ម.ម
- ប្រវែងបញ្ឆិតជ្រុងលើ ២១ ម.ម
- ពីចុងស្រួចមកផ្នែកកណ្តាលនៃនិមិត្តសញ្ញារបស់បណ្ឌិត្យសភានគរបាលកម្ពុជា ៨.៥ ម.ម ។

សញ្ញាកអាវ រាងទ្រវែង ខាងដើមរាងមូល និងខាងចុងស្រួច ធ្វើពីក្រណាត់មានប៉ាក់ ផ្ទៃពណ៌ដូចម្លូក និងមានរឹមពណ៌ទឹកប្រាក់ព័ទ្ធជុំវិញ ផ្នែកខាងក្រោមមានអក្សរមូល សរសេរថា «ឌ» និងលេខ ពណ៌ទឹកប្រាក់ ដែលបញ្ជាក់ពីជំនាន់របស់និស្សិតឬសិស្សនគរបាលជាតិ កំពុងសិក្សា ។ សញ្ញាកអាវនេះ សម្រាប់ដេរភ្ជាប់នៅលើកអាវខាងឆ្វេង ។

ខ្នាតសញ្ញាកអាវខាងឆ្វេង ៖

- បណ្តោយ ៥២ ម.ម
- ទទឹង ៣២ ម.ម
- ប្រវែងបញ្ឆិតជ្រុងលើ ២១ ម.ម
- អក្សរ «ជ» និងលេខ កម្ពស់ ១៣ ម.ម
- ពីចុងស្រួចមកអក្សរ «ឌ» ១២ ម.ម ។

៦- ផ្លាក និង ស្លាកឈ្មោះ

-ចំពោះឯកសណ្ឋានសិក្សា ៖ ផ្លាកឈ្មោះ ធ្វើពីលោហៈ ផ្ទៃពណ៌ខៀវចាស់ មានអក្សរពីរជួរ និងមានស៊ុមពណ៌ទឹកប្រាក់ព័ទ្ធជុំវិញ បណ្តោយ ៨៩ ម.ម និងទទឹង ១៩ ម.ម ។ ផ្លាកឈ្មោះនេះ សម្រាប់ពាក់នៅលើហោប៉ៅអាវខាងស្តាំ ។

-ចំពោះឯកសណ្ឋានហ្វឹកហាត់ ៖ ស្លាកឈ្មោះ ធ្វើពីក្រណាត់មានប៉ាក់ ផ្ទៃពណ៌បៃតងចាស់ មានអក្សរពីរជួរ និងមានរឹមពណ៌ទឹកប្រាក់ព័ទ្ធជុំវិញ បណ្តោយ ១០៥ ម.ម និងទទឹង ២៥ ម.ម ។ ស្លាកឈ្មោះនេះ សម្រាប់ដេរភ្ជាប់នៅលើហោប៉ៅអាវលើផ្នែកខាងស្តាំ ។

ជួរទី១ មានអក្សរមូលសរសេរឈ្មោះ និស្សិត ឬ សិស្សនគរបាលជាតិ ជាអក្សរខ្មែរ និងជួរទី២ សរសេរពីអត្តលេខនិស្សិត ឬ សិស្សនគរបាលជាតិ ជាលេខខ្មែរ ដែលកំណត់ដោយបណ្ឌិត្យសភានគរបាលកម្ពុជា ។

**ប្រការ៧.–**

ឯកសណ្ឋាន និង សញ្ញាសម្គាល់ នៃឯកសណ្ឋាននិស្សិតនិងសិស្សនគរបាលជាតិ មានអត្ថន័យដូចខាងក្រោម ៖

១-ឯកសណ្ឋាន ត្រូវបានរចនាឡើងតាមលក្ខណៈស្រដៀងឯកសណ្ឋានរបស់កម្លាំងនគរបាលជាតិ ដែលមានន័យថា និស្សិតនិងសិស្សនគរបាលជាតិកំពុងត្រៀមខ្លួនក្លាយជាមន្ត្រីនគរបាលជាតិ ។

២-មួកកាស្កេតសម្រាប់បុរស មួកសំបុកសម្រាប់នារី និងមួកប៉េរ៉េត៍ ត្រូវបានរចនាឡើងស្របតាមទម្រង់នៃមួកនគរបាលជាតិ ដែលពណ៌មួក និងពណ៌ផ្ទៃសញ្ញាស្មាអាវ កំណត់តាមកម្រិត និងឆ្នាំសិក្សា ។

ក-មួកមានវណ្ឌពណ៌ទឹកមាស ពណ៌មួក និងពណ៌ផ្ទៃសញ្ញាស្មាអាវ កំណត់ដូចខាងក្រោម ៖

- ពណ៌ក្រហម សម្គាល់និស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ឆ្នាំទី២
- ពណ៌ត្នោត សម្គាល់និស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ឆ្នាំទី១

ខ-មួកមានវណ្ឌពណ៌ទឹកប្រាក់ ពណ៌មួក និងពណ៌ផ្ទៃសញ្ញាស្មាអាវ កំណត់ដូចខាងក្រោម ៖

- ពណ៌ខៀវ សម្គាល់និស្សិតថ្នាក់បរិញ្ញាបត្រ ឆ្នាំទី៤
- ពណ៌ស្វាយ សម្គាល់និស្សិតថ្នាក់បរិញ្ញាបត្រ ឆ្នាំទី៣
- ពណ៌បៃតង សម្គាល់និស្សិតថ្នាក់បរិញ្ញាបត្រ ឆ្នាំទី២
- ពណ៌ទឹកក្រូច សម្គាល់និស្សិតថ្នាក់បរិញ្ញាបត្រ ឆ្នាំទី១

គ-មួកមានវណ្ឌពណ៌ផ្ទៃមេឃ ពណ៌មួក និងពណ៌ផ្ទៃសញ្ញាស្មាអាវ មានពណ៌លឿង សម្គាល់សិស្សនគរបាលជាតិ ។

៣-ព្រះសង្ហារស្ថិតនៅលើមុខមួក មានន័យថាការតម្កល់ផលប្រយោជន៍ជាតិជាធំ ដោយគោរពតាមបាវចនា «ជាតិ សាសនា ព្រះមហាក្សត្រ» ។

៤-និមិត្តសញ្ញាបណ្ឌិត្យសភានគរបាលកម្ពុជា តំណាងឱ្យអង្គភាពបណ្តុះបណ្តាលកងកម្លាំងនគរបាលជាតិ ។

**ប្រការ៨ .—**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍ ។

**ប្រការ៩ .—**

អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាល អគ្គស្នងការនៃអគ្គស្នងការដ្ឋាននគរបាលជាតិ អគ្គាធិការនៃអគ្គាធិការដ្ឋាន អគ្គនាយកនៃអគ្គនាយកដ្ឋានកស្តុភារនិងហិរញ្ញវត្ថុ ប្រធានបណ្ឌិត្យសភានគរបាលកម្ពុជា អគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធនាគារ អគ្គនាយកនៃអគ្គនាយកដ្ឋានអន្តោប្រវេសន៍ អគ្គនាយកនៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម អគ្គនាយកនៃអគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង ប្រធានក្រុមប្រឹក្សានីតិកម្ម អភិបាលនៃគណៈអភិបាលរាជធានី-ខេត្ត ប្រធាននាយកដ្ឋានបុគ្គលិក និងប្រធានអង្គភាពសាមីពាក់ព័ន្ធចំណុះក្រសួងមហាផ្ទៃ ត្រូវទទួលអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ថ្ងៃពុធ ៤ រោច ខែភទ្របទ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែកក្កដា ឆ្នាំ២០១៩

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**សម្តេចក្រឡាហោម ស ខេង**

**កន្លែងទទួល ៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងអប់រំ យុវជន និងកីឡា
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចក្រឡាហោម ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ
- ដូចប្រការ៩
- ឯកសារ-កាលប្បវត្តិ

ឧបសម្ព័ន្ធ នៃប្រកាសលេខ ៧៤៩៧ ប្រ.ក ចុះថ្ងៃទី ២៤ ខែ កក្កដា ឆ្នាំ ២០១៩
ស្តីពីការបង្កើតឯកសណ្ឋាន និង សញ្ញាសម្គាល់ សម្រាប់និស្សិតនិងសិស្សនគរបាលជាតិ
នៃបណ្ឌិត្យសភានគរបាលកម្ពុជា

## គំរូឯកសណ្ឋាន និង គំរូសញ្ញាសម្គាល់

## I. សញ្ញាសម្គាល់

### ព្រះសង្ខារ

**សម្រាប់មួកកាស្កេត** | **សម្រាប់មួកសំប៉ុក** | **សម្រាប់មួកប៉េរ៉េត៍**

៧១ ម.ម



៧៨ ម.ម

៥៤ ម.ម



៥៣ ម.ម

៥៥ ម.ម



៤៥ ម.ម

### បន្ទោងនិមិត្តសញ្ញាបណ្ឌិត្យសភានគរបាលកម្ពុជា

**សម្រាប់ឯកសណ្ឋានសិក្សា ធ្វើពីលោហៈ** | **សម្រាប់ឯកសណ្ឋានហ្វឹកហាត់ ធ្វើពីក្រណាត់ (ប៉ាក់)**




៤៩ ម.ម ១០០ ម.ម




៤៩ ម.ម ១០០ ម.ម

## ស្លាកសញ្ញានិស្សិត និង សិស្សនគរបាលជាតិ





## ស្លាកសញ្ញាបណ្ឌិត្យសភានគរបាលកម្ពុជា





## ផ្លាក និង ស្លាកឈ្មោះ មានឈ្មោះ និងអត្តលេខ

### សម្រាប់ឯកសណ្ឋានសិក្សា ធ្វើពីលោហៈ





### សម្រាប់ឯកសណ្ឋានហ្វឹកហាត់ ធ្វើពីក្រណាត់ (ប៉ាក់)





## II. ខ្សែក្រវាត់ និង ស្បែកជើង

### ខ្សែក្រវាត់



### ខ្សែក្រវាត់សាំងទៀរ៉ុង



### ស្បែកជើងបុរស ស្បែកជើងនារី ស្បែកជើងកវែង



# III. ឯកសណ្ឋាន សម្រាប់និស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់

## ១. ឯកសណ្ឋាន សម្រាប់និស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ឆ្នាំទី២

### ក. ឯកសណ្ឋានសិក្សា សម្រាប់បុរស

មួកកាស្កេត (ពណ៌ក្រហម)



សញ្ញាស្មាអាវ







សញ្ញាកអាវ





## ខ. ឯកសណ្ឋានហ្វឹកហាត់ សម្រាប់បុរស

### មួកបេរ៉េត៍ (ពណ៌ក្រហម)



### សញ្ញាកអាវ






## គ. ឯកសណ្ឋានសិក្សា សម្រាប់នារី

**មួកសំបុក (ពណ៌ក្រហម)** **សញ្ញាស្មារអាវ** **សញ្ញាកអាវ**










## ឃ. ឯកសណ្ឋានហ្វឹកហាត់ សម្រាប់នារី

### មួកបេរ៉េត៍ (ពណ៌ក្រហម)



### សញ្ញាកអាវ






## ២. ឯកសណ្ឋាន សម្រាប់និស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ឆ្នាំទី១

### ក. ឯកសណ្ឋានសិក្សា សម្រាប់បុរស

**មួកកាស្កេត (ពណ៌ត្នោត)** **សញ្ញាស្មារអាវ** **សញ្ញាកអាវ**











## ខ. ឯកសណ្ឋានហ្វឹកហាត់ សម្រាប់បុរស

### មួកប៊េរ៉េត់ (ពណ៌ត្នោត)



### សញ្ញាកអាវ






## គ. ឯកសណ្ឋានសិក្សា សម្រាប់នារី

### មួកសំបុក (ពណ៌ត្នោត)



### សញ្ញាស្មារអាវ




### សញ្ញាកអាវ






## ឃ. ឯកសណ្ឋានហ្វឹកហាត់ សម្រាប់នារី

### មួកប៊េរ៉េត (ពណ៌ត្នោត)



### សញ្ញាកអាវ






# IV. ឯកសណ្ឋាន សម្រាប់និស្សិតថ្នាក់បរិញ្ញាបត្រ

## ១. ឯកសណ្ឋាន សម្រាប់និស្សិតថ្នាក់បរិញ្ញាបត្រ ឆ្នាំទី៤

### ក. ឯកសណ្ឋានសិក្សា សម្រាប់បុរស

**មួកកាស្កេត (ពណ៌ខៀវ)**



**សញ្ញាស្មាអាវ**




**សញ្ញាកអាវ**






## ខ. ឯកសណ្ឋានហ្វឹកហាត់ សម្រាប់បុរស

### មួកប៉េរ៉េត (ពណ៌ខៀវ)



### សញ្ញាកអាវ






## គ. ឯកសណ្ឋានសិក្សា សម្រាប់នារី

**មួកសំប៉ុក (ពណ៌ខៀវ)**



**សញ្ញាស្មាអាវ**







**សញ្ញាកអាវ**






## ឃ. ឯកសណ្ឋានហ្វឹកហាត់ សម្រាប់នារី

### មួកប៉េរ៉េត៍ (ពណ៌ខៀវ)



### សញ្ញាកអាវ






## ២. ឯកសណ្ឋាន សម្រាប់និស្សិតថ្នាក់បរិញ្ញាបត្រ ឆ្នាំទី៣

### ក. ឯកសណ្ឋានសិក្សា សម្រាប់បុរស

**មួកកាស្កេត (ពណ៌ស្វាយ)**



**សញ្ញាស្មាអាវ**




**សញ្ញាកអាវ**






## ខ. ឯកសណ្ឋានហ្វឹកហាត់ សម្រាប់បុរស

### មួកប៉េរ៉េត៍ (ពណ៌ស្វាយ)



### សញ្ញាកអាវ






## គ. ឯកសណ្ឋានសិក្សា សម្រាប់នារី

### មួកសំប៉ុក (ពណ៌ស្វាយ)



### សញ្ញាស្មាអាវ







### សញ្ញាកអាវ






## ឃ. ឯកសណ្ឋានហ្វឹកហាត់ សម្រាប់នារី

### មួកបេរ៉េត៍ (ពណ៌ស្វាយ)



### សញ្ញាកអាវ






## ៣. ឯកសណ្ឋាន សម្រាប់និស្សិតថ្នាក់បរិញ្ញាបត្រ ឆ្នាំទី២

### ក. ឯកសណ្ឋានសិក្សា សម្រាប់បុរស

**មួកកាស្កេត (ពណ៌បៃតង)** | **សញ្ញាស្មាអាវ** | **សញ្ញាកអាវ**













## ខ. ឯកសណ្ឋានហ្វឹកហាត់ សម្រាប់បុរស

### មួកប៉េរ៉េ (ពណ៌បៃតង)



### សញ្ញាកអាវ






# គ. ឯកសណ្ឋានសិក្សា សម្រាប់នារី

**មួកសំប៉ុក (ពណ៌បៃតង)** **សញ្ញាស្មាអាវ** **សញ្ញាកអាវ**











## ឃ. ឯកសណ្ឋានហ្វឹកហាត់ សម្រាប់នារី

### មួកប៉េរ៉េត៍ (ពណ៌បៃតង)



### សញ្ញាកអាវ






## ៤. ឯកសណ្ឋាន សម្រាប់និស្សិតថ្នាក់បរិញ្ញាបត្រ ឆ្នាំទី១

### ក. ឯកសណ្ឋានសិក្សា សម្រាប់បុរស

**មួកកាស្កេត (ពណ៌ទឹកក្រូច)**



**សញ្ញាស្មាអាវ**




**សញ្ញាកអាវ**





## ខ. ឯកសណ្ឋានហ្វឹកហាត់ សម្រាប់បុរស

**មួកប៉េរ៉េ (ពណ៌ទឹកក្រូច)**



**សញ្ញាកអាវ**









## គ. ឯកសណ្ឋានសិក្សា សម្រាប់នារី

**មួកសំបុក (ពណ៌ទឹកក្រូច)**



**សញ្ញាស្មាអាវ**







**សញ្ញាកអាវ**





## ឃ. ឯកសណ្ឋានហ្វឹកហាត់ សម្រាប់នារី

### មួកប៉េរ៉េត៍ (ពណ៌ទឹកក្រូច)



### សញ្ញាកអាវ









## V. ឯកសណ្ឋាន សម្រាប់សិស្សនគរបាលជាតិ

### ក. ឯកសណ្ឋានសិក្សា សម្រាប់បុរស

**មួកកាស្កេត (ពណ៌លឿង)** **សញ្ញាស្មាអាវ** **សញ្ញាកអាវ**













## ខ. ឯកសណ្ឋានហ្វឹកហាត់ សម្រាប់បុរស

**មួកប៊េរ៉េ (ពណ៌លឿង)**



**សញ្ញាកអាវ**






## គ. ឯកសណ្ឋានសិក្សា សម្រាប់នារី

### មួកសំប៉ុក (ពណ៌លឿង)



### សញ្ញាស្មារអាវ







### សញ្ញាកអាវ






## ឃ. ឯកសណ្ឋានហ្វឹកហាត់ សម្រាប់នារី

### មួកប៊េរ៉េត (ពណ៌លឿង)



### សញ្ញាកអាវ




